ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល
សំណុំរឿង រដ្ឋប្បវេណី
លេខៈ៣៣៤
ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ១៩៩៨
**សាលដីកា**
លេខៈ៩១
ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៥

តាងនាមប្រជារាស្ត្រខ្មែរ
តុលាការកំពូល
បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៥ ដោយមានសមាសភាពដូចតទៅៈ
១-ឯកឧត្តម ........... ជាប្រធាន
២-លោក ............ ជាចៅក្រម
៣-លោក ............ ជាចៅក្រម
៤-លោក ............ ជាចៅក្រម
៥-លោក ............ ជាចៅក្រមរបាយការណ៍
៦-លោក ............ ជាចៅក្រម
៧-លោក ............ ជាចៅក្រម
៨-លោក .............. ជាចៅក្រម
៩-លោក .............. ជាចៅក្រម

**ក្រឡាបញ្ជី**
-លោក ..................

**តំណាងមហាអយ្យការ**
-លោក .............. ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីការដ្ឋប្បវេណីលេខ៥៧៤ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ៩៨ នៃសំណុំរឿងរដ្ឋប្បវេណីលេខ៣៦ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ១៩៩៧ របស់សាលាឧទ្ធរណ៍រវាងៈ

ដើមចោទឈ្មោះភហ (ចុងបណ្តឹងសាទុក្ខ) ភេទស្រី អាយុ៦៥ឆ្នាំ ជាតិខ្មែរ របរធ្វើស្រែ ទីលំនៅសព្វថ្ងៃ ភូមិស្រែព្រីង ឃុំលេខ២ ស្រុកកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង ។ ឳពុកឈ្មោះភោគ កិល (ស) ម្តាយឈ្មោះ ហូ(ស) ។

ផ្ទេរសិទ្ធិឱ្យកូនឈ្មោះ សស ។

លោក ......... ជាមេធាវី ។

និងចុងចម្លើយឈ្មោះឡហ (ម្ចាស់បណ្ដឹងសាទុក្ខ) គេទស្រីអាយុ៥៦ឆ្នាំ ជាតិខ្មែរ របរធ្វើស្រែ ទីលំនៅសព្វថ្ងៃ ភូមិស្រែព្រីង ឃុំលេខ២ ស្រុកកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង ។ ឪពុកឈ្មោះឡាង អុង (ស) ម្ដាយឈ្មោះ សុន (ស) ។

ផ្ទេរសិទ្ធិឱ្យកូនឈ្មោះ ឈសណា ។

លោក ............ ជាមេធាវី ។

**<u>កម្មវត្ថុបណ្ដឹង :</u>** ប្ដឹងសុំគ្រប់គ្រងដី និងផ្ទះ

បានឃើញបណ្ដឹងសាទុក្ខលើកទី២លេខ៣៥៦ ចុះថ្ងៃទី០៥ ខែតុលាឆ្នាំ១៩៩៨ របស់ឈ្មោះឈសណា បានប្ដឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ៥៧៤ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍លើចំណុចសេចក្ដីសម្រេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ៣៣៤ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ១៩៩៨ របស់តុលាការកំពូល ។

តាមពាក្យបណ្ដឹងចុះថ្ងៃទី២១-០៣-១៩៩៤ របស់ឈ្មោះភហ ប្ដឹងសុំសិទ្ធិគ្រប់គ្រងផ្ទះ និងដីភូមិដោយសំអាងហេតុថា ខ្លួនបានគ្រប់គ្រងដីដែលមានទំហំ២៨ម៉ែត្រ គុណ នឹង១០០ម៉ែត្រតាំងពីឆ្នាំ១៩៧៩ មកម្ល៉េះ លុះដល់ឆ្នាំ១៩៨៤ ឈ្មោះឡហ បានមកធ្វើរបងកាត់ប្លង់ដីរបស់ខ្លួនជាង៣ក់ កណ្ដាលហើយសង់ផ្ទះបាយលើដីខ្លួនទៀត មកឆ្នាំ១៩៩៣ ឈ្មោះនេះបានឱ្យកូនសង់ផ្ទះធំលើដីនេះបន្ថែម ទៀតហើយក្រុមគ្រួសារនេះ បានបង្ខិតរបងចូលអស់ប្រវែង២ម៉ែត្រថែមទៀត ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ១៧ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ១៩៩៥ របស់តុលាការ ខេត្តកំពង់ឆ្នាំង ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ :

១-ទទួលពាក្យបណ្ដឹងចុះថ្ងៃទី២១-០៣-១៩៩៤ របស់ឈ្មោះភហ ដើមចោទសុំសិទ្ធិគ្រប់គ្រងដីទំនាស់ជាកម្មសិទ្ធិ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

-ទទួលយកសំណូមពរ ប្ដឹងសុំនាពេលសវនាការ របស់ដើមចោទទាមទារសុំកាន់កាប់ដី ទំហំ២៨ម៉ែត្រ គុណ ១០០ម៉ែត្រ ជាកម្មសិទ្ធិ និងសុំឱ្យចុងចម្លើយរុះរើផ្ទះចេញពីដីទំនាស់ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

-បដិសេធចោល និងសំណូមពរ ប្ដឹងសុំនាពេលសវនាការរបស់ចុងចម្លើយសុំកាន់កាប់ ដីទំនាស់ និងសុំធ្វើរបងបិទភ្ជិតដីទំនាស់ ដោយផ្ទុយនឹងគតិច្បាប់ ។

២-ប្រគល់ដីទំនាស់ទំហំ២៨ម៉ែត្រ គុណ ១០០ម៉ែត្រ ដែលមានទីតាំងព្រំប្រទល់ខាង កើតទល់នឹងថ្នល់ជាតិ ខាងលិចទល់នឹងផ្លូវរទេះ.ខាងជើងទល់នឹងដីរបស់ឈ្មោះសេក សេន ខាងត្បូងជាប់នឹងដីឈ្មោះឈឹម ចាន់ណា ស្ថិតនៅភូមិស្រែព្រីង ឃុំលេខ២ ទីរួមខេត្ត-ខេត្តកំពង់ឆ្នាំង ឱ្យដល់ឈ្មោះភហ ជាកម្មសិទ្ធិចាប់តាំងពីថ្ងៃប្រកាសសាលក្រមនេះ ចូលជាស្ថាពរ ។

តាមមាត្រាទី៣ ១៩, ២០. ៦២ ៦៤ ៦៥, ៦៨, ៧១ និងមាត្រា៧៤ នៃច្បាប់ភូមិបាល ដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ១០០ក្រ ចុះថ្ងៃទី១៣-១០-១៩៩២ របស់ក្រុមប្រឹក្សារដ្ឋនៃរដ្ឋកម្ពុជា

ឱ្យឈ្មោះឡូហ រុះរើសំណង់ផ្ទះដែលសាម៉ីខ្លួនបានសាងសង់នៅលើដីកម្មសិទ្ធិ របស់ឈ្មោះ ភហ ក្នុងរយៈពេល១ខែ គិតពីថ្ងៃសាលក្រមចូលជាស្ថាពរ តាមច្បាប់ភូមិបាលត្រង់មាត្រា២៨ ។

-ឱ្យឈ្មោះឡូហ បង់ប្រាក់ប្រដាប់ក្តី គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន១.៨០០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ចំនួន២០០៛ រង្វាន់អ្នកប្រគល់ដីកាកោះចំនួន៥.០០០៛ បូកសរុបចំនួន ៧.០០០ប្រាក់នេះត្រូវបានកាត់ពីប្រាក់ចំនួន៧.០០០៛ ដែលដើមចោទបានបង់រួចហើយ កាលបើសាលក្រមនេះចូលជាស្ថាពរ ឱ្យចុងចម្លើយសងប្រាក់នេះទៅដើមចោទវិញ ។

និងឱ្យបង់ពន្ធសមាមាត្រគិតជាប្រាក់រៀលចំនួន៦០០០០៛ ដោយដាក់ជាប្រយោជន៍ នៃថវិការដ្ឋចំនួន៨០%និងដាក់ចូលហិបប្រាក់ក្រឡាបញ្ជីទូទាំងប្រទេសចំនួន២០%បើសាលក្រមនេះចូលជាស្ថាពរ។

តាមច្បាប់ស្តីពីប្រាក់ប្រដាប់ក្តី ដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ០៧ក្រ ចុះថ្ងៃទី០៨-០២-១៩៩៣ របស់ក្រុមប្រឹក្សារដ្ឋនៃរដ្ឋកម្ពុជា ។

សាលក្រមប្រកាសជាសាធារណៈ ចំពោះមុខគូភាគី បើកផ្លូវឧទ្ធរណ៍កំណត់ពីរខែ គិត ពីថ្ងៃនេះតទៅ ។

បានឃើញបណ្តឹងឧទ្ធរណ៍របស់ឈ្មោះឡូហ ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ១៩៩៥ ប្តឹងមិនសុខ ចិត្តលើសេចក្តីសម្រេច នៃសាលក្រមទាំងមូល ។

បានឃើញសាលដីការបស់សាលាឧទ្ធរណ៍លេខ៤៣២ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៦ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលបណ្តឹងឧទ្ធរណ៍របស់ឈ្មោះឡូហ ចុះថ្ងៃទី០១-០៣-១៩៩៥ ទុកជាត្រឹម ត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-បដិសេធសាលក្រមរដ្ឋប្បវេណីលេខ១៧ ចុះថ្ងៃទី២០-០២-១៩៩៥ របស់តុលាការខេត្តកំពង់ឆ្នាំង ចោលជាអសារបង់ ។

៣-រឹបអូសប្រាក់ប្រដាប់ក្តី ជាន់សាលាឧទ្ធរណ៍ចំនួន១៣.០០០៛ ដែលដើមបណ្តឹងឧទ្ធរណ៍បានបង់រួចហើយគឺ :

-ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹង២៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០៛ ចំណាយលើការប្រគល់ដីកាកោះ៥.០០០៛ និងអាជ្ញាធរតុលាការ៥.០០០៛ ។ កាលបើផុតកំណត់ប្តឹងសាទុក្ខបង្គាប់ឱ្យចុងបណ្តឹងឧទ្ធរណ៍សងប្រាក់នេះទៅដើមបណ្តឹងឧទ្ធរណ៍វិញ ។

៤-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខគូក្តី បើកផ្លូវប្តឹង សាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ៣៣២ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ១៩៩៦ របស់ឈ្មោះសស ទទួលសិទ្ធិពីឈ្មោះភហ ប្តឹងមិនសុខចិត្ត នឹងសាលដីការដ្ឋប្បវេណីលេខ៨៣២ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៦ របស់សាលាឧទ្ធរណ៍ទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ១២៦ ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ១៩៩៧ របស់តុលាការកំពូល ដែលមានខ្លឹមសារ នៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលបណ្តឹងសាទុក្ខលេខ៣៣២ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ១៩៩៦ របស់លោកសស ទទួលសិទ្ធិពីអ្នកស្រីភាគ ហ៊ុន ទុកជាត្រឹមត្រូវ តាមទម្រង់ និងគតិច្បាប់ ។

២-ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ៤៣២ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៦ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ៣៦ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ១៩៩៧ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤-រឹបអូសប្រាក់ប្រដាប់ក្តីជាន់តុលាការកំពូលចំនួន១៥.០០០៛ ដែលអ្នកស្រីភហ បានបង់ទុកជាមុនគឺ :

-ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន៤០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០៛ សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ .

-ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០៛ សរុប១៩.០០០៛ ហើយតម្រូវ ឱ្យអ្នកស្រីឡហ សងប្រាក់ចំនួន១៩.០០០៛ ទៅអ្នកស្រីភហ វិញ ។

៥-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ១៩៩៧ ។

បានឃើញដីកាបញ្ជូនលេខ៣២៥/៩៧ សរណ ចុះថ្ងៃទី០៣-០៩-១៩៩៧ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍វិញ ដើម្បីចាត់ការតាមច្បាប់ ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៥៧៤ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលជំនុំជំរះសំណុំរឿងរដ្ឋប្បវេណីលេខ៣៦ ចុះថ្ងៃទី១៧-០៩-១៩៩៧ របស់សាលាឧទ្ធរណ៍តាមអំណាចសាលដីការបស់តុលាការកំពូលលេខ១២៦ ចុះថ្ងៃទី២៤-០៧-១៩៩៧ ។

២-ប្រគល់ដីទំនាស់ទំហំក្បាល២៦,២៧គុណបណ្តោយ៧៧.៤៥ម៉ែត្រ ស្ថិតនៅក្នុងភូមិស្រែព្រីង ឃុំទី២ ទីរួមខេត្តកំពង់ឆ្នាំង តាមប្លង់បង្ហាញទីតាំងដីទំនាស់លេខ០៦/៩៦ ចុះថ្ងៃទី២២-០៧-១៩៩៦ របស់ការិយាល័យភូមិបាល ស្រុកកំពង់ឆ្នាំងឱ្យទៅឈ្មោះភហ កាន់កាប់និងគ្រប់គ្រងជាកម្មសិទ្ធិនៅពេលដែលសាលដីកានេះចូលជាស្ថាពរ ។

បង្គាប់ឱ្យឈ្មោះឡហ រុះរើសំណង់ផ្ទះដែលសាមីខ្លួនបានសង់នៅលើដីទំនាស់នោះចោលចេញនៅពេលដែលសាលដីកានេះចូលជាស្ថាពរ ។

៣-បង្គាប់ឱ្យឈ្មោះឡហ បង់ពន្ធសមាមាត្រ១% លើតម្លៃដីទំនាស់ក្បាល២៦,២៧គុណបណ្តោយ ៧៧.៤៥ម៉ែត្រ ។ ៳

៤-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈ ចំពោះមុខគូក្តី ។ បើកផ្លូវ សាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលើកទី២លេខ៣៥៦ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៨ របស់អ្នកស្រីឈឹម ស៊ីវណ្ណ ប្តឹងមិនសុខចិត្ត នឹងសាលដីការដ្ឋប្បវេណីលេខ៥៧៤ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ លើសាលដីកាទាំងមូល ។

បានឃើញសារណាការពារចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ១៩៩៩ របស់អ្នកស្រីឈឹម ស៊ីវណ្ណ ។

បានឃើញសារណាឆ្លើយតប ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ១៩៩៩ របស់អ្នកស្រីភហ ។

បានឃើញសាលដីការដ្ឋប្បវេណីរបៀបលេខ២០០ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០២ របស់តុលាការកំពូល ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ចាត់របៀបឱ្យចៅក្រមប្រឹក្សាតុលាការកំពូល ចុះពិនិត្យដល់ទីតាំងទំនាស់ ក្នុងករណីចាំបាច់ត្រូវធ្វើការស៊ើបអង្កេត បន្ថែម ។

២-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០០២ ។

បានឃើញសាលដីការដ្ឋប្បវេណីរបៀបលេខ១០៧ ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០០៣ របស់តុលាការកំពូល ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ចាត់របៀបឱ្យធ្វើការស៊ើបអង្កេតបញ្ជាក់បន្ថែម ។

២-សាលដីតានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០០៣ ។

បានស្តាប់របាយការណ៍បន្ថែមរបស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថាៈ រឿងនេះជារឿងវិវាទប្តឹងទាមទារដី។

សូមក្រុមប្រឹក្សាជំនុំជំរះ សម្រេចតាមច្បាប់ ។

បានស្តាប់ចម្លើយរបស់ឈ្មោះឈឹម ស៊ីវណ្ណ (ជាម្ចាស់បណ្តឹងសាទុក្ខ) បានឆ្លើយនាពេលសវនាការថា ខ្លួនកើតទុក្ខមិនសុខចិត្ត ព្រោះការសម្រេចសេចក្តីរបស់សាលាឧទ្ធរណ៍មិនមានភាពយុត្តិធម៌ ខ្លួនសូមជម្រាបជូនឯកឧត្តមឲ្យបានជ្រាបថា ដីទំនាស់នេះខ្លួនបានមករស់នៅតាំងពីថ្ងៃទី១៤ ខែមករា ឆ្នាំ១៩៧៩ មកម្ល៉េះ ការកាន់កាប់មានទំហំ៣៩មx១០០ម ។ លុះក្រោយមកអ្នកស្រីភហ បានមកខ្ចីដីរបស់ខ្លួនស្នាក់នៅ ជាបណ្តោះអាសន្ន ឪពុកខ្លួនបានឲ្យគាត់ស្នាក់នៅលើដីជ្រុងខាងមុខ ផ្នែកខាងជើងសង់ផ្ទះនៅជាបណ្តោះអាសន្ន ។ ក្រោយមកទៀតនៅឆ្នាំ១៩៨០ ឈ្មោះភហ គាត់មិនត្រឡប់ទៅស្រុកកំណើតនៅភូមិគ្រួ

សជើងគ្រាវិញទេ ហើយឈ្មោះនេះបានសុំអនុញ្ញាត្តិពីឪពុកម្តាយខ្លួននៅបន្តទៀត ។ នៅឆ្នាំ១៩៨០ ដដែលឪពុកខ្លួនក៏សម្រេចប្រគល់ដី ចែកឱ្យទៅឈ្មោះភហ ស្នាក់នៅជាបណ្តោះអាសន្នទំហំ២៣មគុណ ៣២ម និងមានព្រំប្រទល់ :

-ខាងកើតទល់នឹងផ្លូវជាតិលេខ៥

-ខាងត្បូងកំណត់ព្រំគោលដើមមៀន

-ខាងលិចកំណត់ត្រឹមគោលដើមសណ្តាន់កាត់ទទឹងទៅជើង

-ខាងជើងទល់ដីលោកសេក សេង ។ ការរស់នៅប្រកបដោយភាពសុខសាន្ត មិនដែលមានទំនាស់ឡើយ ។ នៅឆ្នាំ១៩៩១ ឆ្នាំ១៩៩២ ឪពុកខ្លួនគាត់បានចាក់ដី១០០ រទេះកាច់ ក្រោយមកគាត់បានរុះរើផ្ទះចាស់ ហើយបានសង់ផ្ទះថ្មី ដែលមានទំហំ៦មគុណ១១ម,ធ្វើពីឈើប្រក់ហ្វីប្រូ ។ ចំពោះដំណាំ និងការបេះផលដំណាំ គឺក្រុមគ្រួសារខ្លួនជាអ្នកកាន់កាប់ និ បេះផលរហូតដល់សព្វថ្ងៃនេះ ហើយអណ្តូងទឹកក៏ក្រុមគ្រួសារខ្លួន ជាអ្នកថែរក្សា និងប្រើប្រាស់ដែរ ។ លុះដល់ឆ្នាំ១៩៩៣ ទើបមានវិវាទកើតឡើង ហើយនៅឆ្នាំ១៩៩៤ ទើបអ្នកស្រីភហ បានប្តឹងទៅតុលាការខេត្តកំពង់ឆ្នាំង ។ ខ្លួនសូមសំណូមពរឲ្យតុលាការក្សាព្រំដីចាស់របស់ខ្លួននៅដដែល ។

បានស្តាប់ចម្លើយរបស់ឈ្មោះសស (ចុងបណ្តឹងសាទុក្ខ) នៅពេលសវនាការថា: នៅឆ្នាំ១៩៧៩ ក្រោយពីត្រឡប់មកពីរបបប៉ុលពតវិញខ្លួនបានស្នាក់នៅលើដីទំនាស់នេះ ដែលមានទទឹង២៨ម បណ្តោយ ១០០ម ដែលមានព្រំប្រទល់ខាងកើតទល់ផ្លូវជាតិ ខាងលិចទល់ផ្លូវរទេះ ខាងជើងទល់ដីឈ្មោះសេក សេន ខាងត្បូងទល់ដី ឈឹម ចាន់ណា ។ នៅឆ្នាំ១៩៨៤ ឈ្មោះឡហ និងក្រុមគ្រួសារបានរំលោភធ្វើរបងកាត់ប្លង់ដីខ្លួនអស់ពាក់កណ្តាលហើយសង់ផ្ទះបាយនៅទីនោះទៀត ទើបខ្លួនប្តឹងភូមិ-ឃុំ ឱ្យជួយដោះស្រាយ ប៉ុន្តែពេលនោះភូមិ-ឃុំ មិនបានដោះស្រាយឱ្យខ្លួនទេ ។ លុះដល់ឆ្នាំ១៩៩៣ ឈ្មោះឡហ និងក្រុមគ្រួសាររើផ្ទះចាស់ ហើយសង់ផ្ទះថ្មីនៅលើដីទំនាស់នោះទៀត រួចហើយបានឲ្យកូនគាត់ឈ្មោះឈឹម ស៊ីវណ្ណ រស់នៅលើដីទំនាស់នោះ ដែលពីមុនឈ្មោះនេះរស់នៅលើដី និងផ្ទះផ្សេង ដែលជាដីមានកម្មសិទ្ធិរបស់ខ្លួន រួចស្រេច ហើយមករស់នៅលើផ្ទះសង់ថ្មី សព្វថ្ងៃនេះ។ ខ្លួនសូមបញ្ជាក់ថា ខ្លួនពុំដែលបានខ្ចីដីពីឈ្មោះឡហ ទេ រហូតមកដល់សព្វថ្ងៃនេះ ដោយមានបញ្ជាក់ពីឈ្មោះស្រី វ៉ាន់ ប្រធានគណកម្មាធិកាប្រជាជនសង្កាត់លេខ២ ទីរួមខេត្ត កំពង់ឆ្នាំង មានក្បាលដី២៨ម៉ែត្រគុណ១០០ម៉ែត្រ ។ ខ្លួនសូមសំណូមពរឲ្យតុលាការកំពូលមេត្តាតម្កល់សាលដីកាលេខ៥៧៤ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ទាំងមូល ។

បានស្តាប់ចម្លើយរបស់ឈ្មោះកង ពត ជាសាក្សីចុងចម្លើយបានស្បថនៅតុលាការកំពូលរួចហើយ នៅពេលសវនាការថា: កាលដើមដំបូងឡើយឈ្មោះចាន់ ណា មករស់នៅមុន ហើយក្រោយមកទៀត ទើប

ឃើញភហ មករស់នៅក្រោយ ។ ក្រោយមកទៀតទើបឃើញគេ ទណ្ឌដីចែកព្រំគ្នា ។ ដល់ពេលស្លាប់យូរៗទៅ ឈ្មោះភហ ទារយកដីទៅខាងក្រោយទៀត ។

បានស្តាប់ចម្លើយរបស់ឈ្មោះឈី សុភាព ជាសាក្សីចុងចម្លើយបានស្បថនៅតុលាការកំពូលរួចហើយ នៅពេលសវនាការថាៈ លោកគ្រូ ចាន់ណា គាត់គ្រប់គ្រងដីរបស់ខ្លួនដែរនៅឆ្នាំ១០៧៩ ខ្លួននៅស្រុកស្រែហើយគ្រូ ចាន់ណា ឱ្យដីខ្លួនសង់ផ្ទះនៅឆ្នាំ១៩៨១ ។ ពេលដែលខ្លួនដើរឆ្លងកាត់ខ្លួនឃើញគ្រូចាន់ណា សង់ផ្ទះឱ្យកូនបងបង្អស់ ។លុះដល់ឆ្នាំ១៩៨៤ ខ្លួនឃើញគាត់រុះរើហើយសង់ផ្ទះឲ្យកូនប្អូនវិញ ។ ខ្លួនសូមបញ្ជាក់ថា គ្រូ ចាន់ណា សង់ផ្ទះពីឆ្នាំ១៩៧៩ ខ្លួនឃើញមែន ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកឡោ ជនធី ជាមេធាវី ការពារឲ្យចុងចម្លើយនៅពេលសវនាការថាខ្លួនសូមរំលឹកនៅអង្គហេតុបន្តិចមុននឹងចូលប្រវត្តិដីដែលពាក់ព័ន្ធនឹងដីកូនក្តីខ្លួនឈ្មោះឈឹម ស៊ីវណ្ណ និងភោគោគ ហ៊ុន ។ ក្រោយពីបានចេញពីវត្តអារញ្ញមកឈ្មោះភហ បានទៅសុំដីរបស់លោកឈឹម ចាន់ណា ដែលជាឪពុករបស់អ្នកស្រីឈឹម ស៊ីវណ្ណ រស់នៅជាបណ្តោះអាសន្ន ។ ក្នុងអំឡុងឆ្នាំ១៩៨០-១៩៨១ ទំនាស់ក៏ កើតមានឡើង គឺដណ្តើមគ្នាបេះផលដំណាំដោយអ្នកស្រីភហ បានមកបេះផ្លែដូងមិនបានសុំពីលោកឈឹមចាន់ ណា ទេ ។ ក្រោយមកទៀតលោកឈឹម ចាន់ណា គាត់ឈប់រើរវល់បានសំណូមពរ ឲ្យរដ្ឋអំណាចមូលដ្ឋានក្នុងឆ្នាំ១៩៨១ មកធ្វើជាសាក្សីដោយបានបោះបង្គោលចែកដីរវាង ភហ និង ឈឹម ចាន់ណា ។ ពេលដែលកំណត់ព្រំដែនរួចហើយ តើមានបញ្ហាអ្វីកើតឡើងឬទេ នៅឆ្នាំ១៩៨១? បើយើងពិនិត្យលើបណ្តឹងយើង ឃើញថា បណ្តឹងវាស្ងប់ស្ងាត់នៅឆ្នាំ១៩៨១ មកម្ល៉េះ ក្រោយមកទើបមានបណ្តឹងចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៩២ និងបណ្តឹងចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៩៤ ។ ក្នុងរយៈពេលគាត់មិនប្តឹងនោះគាត់គ្មានសិទ្ធិធ្វើអ្វីតទៅទៀតទេ គឺគាត់ថ្លោះសិទ្ធិហើយ ។ ម្យ៉ាងទៀតតាមការបញ្ជាក់រដ្ឋអំណាចមូលដ្ឋានបញ្ជាក់ថា ខាងមុខមានដើមមៀន ខាងក្រោយមានដើមសណ្តាន់ ដែលបានបញ្ជាក់ពីព្រំប្រទល់ត្រឹមត្រូវ ។ សរុបសេចក្តីមកផ្អែកតាមអង្គហេតុ ពិតជាមានការរៀបចំព្រំដីនេះពិតប្រាកដមែន ពីឆ្នាំ១៩៨១ រហូតដល់ពេលមានបណ្តឹងពុំបានប្តឹងទៅអាជ្ញាធរទេ បណ្តឹងក្នុងអំឡុង៥ឆ្នាំ មិនប្តឹងទេ គឺផុតអាជ្ញាយុកាលហើយ ។ ខ្លួនជាមេធាវីការពារឱ្យចុងចម្លើយសូមបដិសេធបណ្តឹងទាមទាររបស់ដើមចោទ ទុកជាអាសាបង់ ។

- ក្រោយពីបានស្តាប់របាយការណ៍បន្ថែមរបស់ចៅក្រមរបាយការណ៍
-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
-ក្រោយពីបានស្តាប់ចម្លើយរបស់គូភាគីសាក្សីនិងសេចក្តីសន្និដ្ឋានការពាររបស់មេធាវីចុងចម្លើយ ។
-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលើកទី២លេខ៣៥៦ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៨របស់ឈ្មោះ ឈឹម ស៊ីយ៉ាន ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះ មកជំនុំជំរះដល់អង្គសេចក្តី បានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី និងមាត្រា២២៦ នៃច្បាប់ស្តីពីនីតិវិធី ព្រហ្មទណ្ឌដែលមានអានុភាពអនុវត្តផងដែរ ក្នុងរឿងរដ្ឋប្បវេណី ។៕

-យល់ឃើញថា លទ្ធផលនៃការស៊ើបអង្កេតជាថ្មីតាមអំណាចសាលដីការបៀបលេខ១០៧ ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០០៣ របស់តុលាការកំពូល បានបញ្ជាក់បន្ថែមថា :

+ដីឡូត៍របស់គូភាគី គឺចាប់ពីថ្នល់ជាតិរហូតដល់ផ្លូវរទេះខាងក្រោយ ហើយមានរបងខ័ណ្ឌព្រំ ដោយយករបងថ្មខាងមុខជាគោល ។

+សាក្សីឈ្មោះស្រី វ៉ាន់ ដែលគូភាគីទទួលយកថា ជាអ្នកបានដឹងអំពីប្រវត្តិកាន់កាប់ដីរបស់ខ្លួន បានបញ្ជាក់ក្នុងលិខិតបំភ្លឺថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០៣ ថា ទិដ្ឋភាពជាក់ស្តែងដីវិវាទស្ថិតនៅពីក្រោយផ្ទះ និងជាកន្ទុយដីរបស់ឈ្មោះភហ មែន ពីព្រោះគ្រួសារទាំងពីរមានក្បាលដីជាប់ដោយឡែកៗពីគ្នា និង មានសំរុងជា១០០ម ទល់ផ្លូវរទេះដូចគ្នា ។

+មានភស្តុតាងបញ្ជាក់ទំនាស់ដណ្តើមកាន់កាប់ដីកើតហេតុ ចាប់ផ្តើមតាំងពីរវាងឆ្នាំ១៩៨១ និង ជាបន្តបន្ទាប់រហូតមក ។

-យល់ឃើញថា ការដែលអ្នកស្រីឈឹម ស៊ីវណ្ណ និងមេធាវីលើកឡើងនៅពេលសវនាការនេះថា ដីទំនាស់នេះត្រូវបានរដ្ឋអំណាចមូលដ្ឋានដោះស្រាយ និងបែងចែកគ្នារួចរាល់តាំងពីឆ្នាំ១៩៨០ ឬ ១៩៨១ រួចមក ហើយនោះ ពុំមានភស្តុតាងបញ្ជាក់គួរឱ្យជឿបានទេ ។

-យល់ឃើញថា សាក្សីចុងចម្លើយដែលបានស្បថ ហើយដែលបានឆ្លើយនាពេលសវនាការនេះ គ្រាន់តែ បញ្ជាក់ពីប្រវត្តិដែលខ្លួនដឹងតាមការឃើញ និងការឮប៉ុណ្ណោះ ដែលពុំអាចបញ្ជាក់ស៊ីជំរៅ អាចជាភស្តុតាងគួរឱ្យ តុលាការលើកជាសំអាងបានឡើយ ។

-យល់ឃើញថា មានសាក្សី រដ្ឋអំណាចមូលដ្ឋាន និងមន្ត្រីជំនាញសុរិយាដីស្រុក និងខេត្តបានបំភ្លឺមក ថា ដីទំនាស់ត្រូវបានរដ្ឋអំណាចប្រគល់ឱ្យដើមចោទតាំពីមុខរហូតដល់ក្រោយទល់ផ្លូវរទេះ ប៉ុន្តែមានសាក្សី និងអតីតរដ្ឋអំណាចខ្វះបញ្ជាក់ថា ដីទំនាស់នេះជាដីរបស់ចុងចម្លើយ ។ម្យ៉ាងទៀតការកាន់កាប់លើដីទំនាស់របស់ ចុងចម្លើយ គឺត្រូវបានដើមចោទប្តឹងតវ៉ារហូតមកដែរ ដូច្នេះតុលាការកំពូលគប្បីពិចារណាតាមសមធម៌ធ្វើការបែក ចែកដីទំនាស់នេះជាពីរចំណែក ។

-យល់ឃើញថា ដើម្បីងាយស្រួលក្នុងការអនុវត្តសាលដីកា តុលាការកំពូលគប្បីសម្រេចកំណត់ជាចំណុច E C B G H A D F លើគំនូសប្លង់ទីតាំងដីទំនាស់ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០២ របស់តុលាការ

កំពូល ដោយកំណត់ប្រគល់ផ្នែក A B C D A ប្រគល់ឱ្យដើមចោទ វាស់ចេញពីចំណុច H និង G ដែល AB=23.75m CD=23,30m CG=DH=60mនឹងប្រគល់ផ្នែក C D F E C ដែលនៅសល់ឲ្យចុងចម្លើយ ។

-យល់ឃើញថា ការកាន់កាប់ដាំដុះ និងសាងសង់លើដីទំនាស់ ត្រូវបានធ្វើឡើងក្នុងពេលដែលដើមចោទកំពុងប្តឹងតវ៉ា ដូច្នេះពេលដីនេះត្រូវបានទៅដើមចោទ ចុងចម្លើយមិនត្រូវបានទទួលសំណងអ្វីឡើយ ។

-យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ៥៧៤ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីមកនេះ មានការខុសឆ្គងទាំងទម្រង់ ទាំងគតិច្បាប់ខ្លះ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តីស័ពោះមុខគូក្តី**

១-ទទួលបណ្តឹងសាទុក្ខលើកទី២លេខ៣៥៦ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៨ របស់ឈ្មោះឈឹម ស៊ីយ៉ាន ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ខ្លះ ។

២-ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ៥៧៤ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ ទាំងមូល ។

៣-សម្រេចបែងចែកដីទំនាស់តាមគំនូសប្លង់ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០២ របស់តុលាការកំពូលជាពីរ ចំណែកឱ្យគូភាគីដូចខាងក្រោម :

ក/-ប្រគល់ដីទំហំABCDAឱ្យដើមចោទដោយវាស់ចេញពីចំណុចH និងG ដែល CG=DH=60m។

ខ/-ប្រគល់ដីទំហំ CDFEC ដែលនៅសល់ពីចំណែកដើមចោទ ឲ្យចុងចម្លើយកាន់កាប់ប្រើប្រាស់តទៅ ។

៤-បង្គាប់ឲ្យចុងចម្លើយរុះរើសំណង់ និងការ្យទាំងពួងពីលើចំណែកដីដែលត្រូវបានទៅដើមចោទទៅ ដាក់លើចំណែកដីរបស់ខ្លួនវិញ ដោយមិនអាចទាមទារសោហ៊ុយបង់ខាតអ្វីបានឡើយ ។

៥-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន១៩.០០០រៀល ដែលចុងចម្លើយបានបង់គឺ :

-ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន៤០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០រៀល សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់

-ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០រៀល សរុប១៩.០០០រៀល ។ បង្គាប់ឲ្យគូភាគីបង់ពន្ធសមាមាត្រ១ភាគរយ លើប្រាក់ថ្លៃដីដែលតុលាការកំពូលសម្រេចប្រគល់ឱ្យភាគី ម្ខាងទៀត ។

៦-សាលដីកានេះប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៥ ។